**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង ផែនការ**

លេខ:០១៤៩ ផកប្រ.ក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបំពេញបន្ថែមលើ សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្ដីពីការកែសម្រួលមាត្រា ១២នៃអនុក្រឹត្យស្ដីពីផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៧០អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៧៣ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៧៤ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៧៥ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៧៦ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៧៧ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៧៨ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- បានឃើញប្រកាសអន្តរក្រសួងលេខ ០៧៩ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ

## សម្រេច

**ប្រការ ១.**

ដាក់ឱ្យប្រើប្រាស់ "សេចក្ដីណែនាំបំពេញបន្ថែមលើសេចក្ដីណែនាំបច្ចេកទេស ដូចមាននៅក្នុងប្រកាសអន្តរក្រសួងលេខ ០៧៣ ០៧៤ ០៧៥ ០៧៦ ០៧៧ ០៧៨ និង០៧៩ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ ២០១៧ ស្ដីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់"។

**ប្រការ ២.**

ក្រុមប្រឹក្សា គណៈអភិបាល មេឃុំ ចៅសង្កាត់នៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវចាត់ចែង និង

អនុវត្តជំហានទី១នៃកិច្ចដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនតាមប្រតិទិនដូចខាងក្រោម ៖

- រដ្ឋបាលរាជធានី ខេត្តត្រូវរៀបចំកិច្ចប្រជុំណែនាំអំពីការប្រមូលតម្រូវការអាទិភាពដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៅក្នុងដើមខែមករានៃឆ្នាំនីមួយៗ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំកិច្ចប្រជុំណែនាំបន្តអំពីការប្រមូលតម្រូវការអាទិភាពដល់រដ្ឋបាលឃុំ សង្កាត់ នៅពាក់កណ្ដាល ខែមករា នៃឆ្នាំនីមួយៗ។
- បន្ទាប់ពីទទួលបានការណែនាំ រដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំ និងអនុវត្តកិច្ចដំណើរការប្រមូលតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ ហើយត្រូវចាត់បញ្ជូនបញ្ជីគម្រោងវិនិយោគជាអាទិភាពសម្រាប់ប្រើប្រាស់ថវិកាឃុំ ថវិកាសង្កាត់របស់ខ្លួនទៅក្រុមការងារកសាងផែនការក្រុង ស្រុក ខណ្ឌ យ៉ាងយូរត្រឹមសប្ដាហ៍ទី២ ខែកុម្ភៈ នៃឆ្នាំនីមួយៗ។
- រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំគម្រោងវិនិយោគជាអាទិភាពសម្រាប់ប្រើប្រាស់ថវិការបស់ខ្លួន និងបូកសរុបតម្រូវការគម្រោងវិនិយោគជាអាទិភាពដែលប្រើប្រាស់ថវិកាឃុំ សង្កាត់នៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួន ដើម្បីបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត នៅដើមខែមីនា នៃឆ្នាំនីមួយៗ។
- រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំគម្រោងវិនិយោគជាអាទិភាពសម្រាប់ប្រើប្រាស់ថវិការបស់ខ្លួន និងបូកសរុបតម្រូវការគម្រោងវិនិយោគជាអាទិភាពដែលប្រើប្រាស់ថវិកាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ នៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួន យ៉ាងយូរនៅដំណាច់ខែមីនា នៃឆ្នាំនីមួយៗ។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនឱ្យបានមុនដំណាច់ឆ្នាំនៃឆ្នាំរៀបចំកម្មវិធីវិនិយោគ។

**ប្រការ ៣.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនបញ្ជីគម្រោងវិនិយោគជាអាទិភាពសម្រាប់ប្រើប្រាស់ថវិកាឃុំ ថវិកាសង្កាត់ ថវិកាក្រុង ថវិកាស្រុក ថវិកាខណ្ឌ ថវិការាជធានី ថវិកាខេត្ត ទៅក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត នៅដំណាច់ខែមីនា នៃឆ្នាំនីមួយៗ។

**ប្រការ ៤.-**

ក្រសួងផែនការត្រូវណែនាំជាគោលការណ៍ដល់មន្ទីរផែនការរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធដើម្បីរៀបចំ និងផ្ដល់ទិន្នន័យបច្ចុប្បន្នភាពឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ សម្រាប់ជាមូលដ្ឋានក្នុងការវិភាគស្ថានភាព និងកំណត់តម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។

**ប្រការ ៥.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្ដល់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សេចក្ដីណែនាំបំពេញបន្ថែមនេះឱ្យមានប្រសិទ្ធភាព។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.......................ខែ.............ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ......... ឆ្នាំ២០២.....

| ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ទេសរដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងផែនការ |
|---|---|
| **សម្តេចក្រឡាហោម ស ខេង** | **កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន** |

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ